# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា ព្រះមហាក្សត្រ

ក្រុមការងារថ្នាក់ជាតិខេត្តសៀមរាប

លេខ: ០១ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងក្រុមការងារអចិន្ត្រៃយ៍របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តសៀមរាប

- យោងសេចក្ដីសម្រេចលេខ៣៧សសរ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩ ស្ដីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្ដីណែនាំលេខ០១សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងសមាសភាពក្រុមការងារអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្ដម | ឈៀង យ៉ាណារ៉ា | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្ដម សន្តិបណ្ឌិត | អ៊ុក គឹមលេខ | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. នាយឧត្ដមសេនីយ៍ | ឥត សារ៉ាត់ | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះ | អនុប្រធាន |
| ៤. ឯកឧត្ដម | ឃឹម ប៊ុនសុង | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៥. ឯកឧត្ដម | ទៀ សីហា | អភិបាល នៃគណៈអភិបាលខេត្តសៀមរាប | អនុប្រធានប្រចាំការ |
| ៦. ឯកឧត្ដម | លី វណ្ណសុត្រ | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |



លេខទូរស័ព្ទទំនាក់ទំនង: ០៩៧ ៧០៨ ៩៩៩៩ /០៩៧ ៧៧ ១១ ៨៨៨ / ០១៥ ៧៧ ៧៧ ៨៨ / ០១៥ ៧៧ ៥៥ ២២ / ០១២ ៩៧ ៩៦ ២៨, E-mail: chhen99@yahoo.com

Scanned with CamScanner

**ប្រការ២.**

ក្រុមការងារអចិន្ត្រៃយ៍ ដូចមានចែងក្នុងប្រការ១ខាងលើ មានភារកិច្ចធ្វើជាសេនាធិការជូនប្រធានក្រុមការងារថ្នាក់ជាតិលើការងារសំខាន់ៗ ដូចខាងក្រោម ៖

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ក្រុមការងារថ្នាក់ជាតិ
- ទទួលរបាយការណ៍ ពីក្រុមការងារក្រុង-ស្រុក ខេត្តសៀមរាប ដើម្បីធ្វើការបូកសរុបអំពីសកម្មភាពការងារ ឲ្យបានទៀងទាត់ជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្របតាមការកំណត់របស់រាជរដ្ឋាភិបាល
- សហការជាមួយក្រុមការងារក្រុង-ស្រុក ខេត្តសៀមរាប សិក្សាអំពីក្របខណ្ឌគោលនយោបាយ ក្របខណ្ឌច្បាប់ និងវិធានការណ៍ទូទៅ ក្នុងការដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ក្រុមការងារចុះមូលដ្ឋានគ្រប់ថ្នាក់ ដែលមិនអាចដោះស្រាយបានដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល
- ធ្វើការបូកសរុបវាយតម្លៃអំពីសមិទ្ធផលបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋក្នុងខេត្តសៀមរាប ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចជាក់ស្តែងពីប្រធានក្រុមការងារថ្នាក់ជាតិខេត្តសៀមរាប ។

**ប្រការ៣.**

ត្រូវបានបង្កើតក្រុមលេខាធិការដ្ឋាន ដើម្បីជាសេនាធិការជូនក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. លោក | ង៉ាន់ ភិរុណ | អភិបាលរងខេត្ត | ប្រធាន |
| ២. លោក | សុខ ថុល | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣. លោក | ចឹក គឹមផុន | នាយករង រដ្ឋបាលសាលាខេត្ត | អនុប្រធានប្រចាំការ |
| ៤. លោក | ស្បៀន ប៊ុនធឿន | នាយករង រដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥. លោក | សោម សមស័ក្តិ | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |
| ៦. លោក | អ៊ឹង សុភ័ណ្ឌ | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៧. លោក | ទិព្វ ពិសិទ្ធ | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | សមាជិក |
| ៨. លោក | ស៊ុន ចំណាន | នាយកទីចាត់ការ រដ្ឋបាលសាលាខេត្ត | សមាជិក |
| ៩. លោក | កុសល មករាពិសិទ្ធ | នាយកទីចាត់ការទំនាក់ទំនងសាធារណៈ សហប្រតិបត្តិការ និងអន្តរជាតិ | សមាជិក |
| ១០. លោក | គួច វារីថ្លា | ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាសាលាខេត្ត | សមាជិក |
| ១១. លោក | ស្រី វិសិដ្ឋ | ប្រធានការិយាល័យរបៀប និងឯកសារសាលាខេត្ត | សមាជិក |
| ១២. លោក | ហ៊ុំ ចាយ | ប្រធានការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាព សាធារណៈសាលាខេត្ត | សមាជិក |
| ១៣. លោក | ឡំ សុខាក់ | ប្រធានការិយាល័យស្ថិតិ និងអគ្រានុកូលដ្ឋានសាលាខេត្ត | សមាជិក |
| ១៤. លោក | ខ្វាន់ សុភាព | ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ និងពិធីការសាលាខេត្ត | សមាជិក។ |

**ប្រការ៤.**

ក្រុមលេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ជានាធិនេត្តភាពការងាររដ្ឋបាលប្រចាំថ្ងៃ និងសម្របសម្រួលរៀបចំរាល់កិច្ចប្រជុំរបស់ក្រុមការងារថ្នាក់ជាតិ ក្រុមការងារអចិន្ត្រៃយ៍ និងក្រុមការងារថ្នាក់ខេត្ត



Scanned with CamScanner

- រៀបចំកំណត់ហេតុ គ្រប់រាល់កិច្ចរបស់ក្រុមការងារថ្នាក់ជាតិ និងក្រុមការងារអចិន្ត្រៃយ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដាក់ជូនក្រុមការងារអចិន្ត្រៃយ៍ ពិនិត្យ និងសម្រេច
- បំពេញកិច្ចការផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់ឯកឧត្តម ប្រធានលេខាធិការដ្ឋាន
- លេខាធិការដ្ឋាននេះ មានទីចាត់ការស្ថិតនៅក្នុងសាលាខេត្ត និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្តសៀមរាប។

**ប្រការ៥.**_

រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.**_

ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តសៀមរាប គណៈអភិបាលខេត្ត គណៈអភិបាលក្រុង-ស្រុក ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ ព្រមទាំងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្ត សេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃចន្ទ ៣កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ខេត្តសៀមរាប ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០១៩

**ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តសៀមរាប**

**សម្តេចពិជ័យសេនា ទៀ បាញ់**

ចម្លងជូន
- សាលាខេត្តសៀមរាប
- ដូចប្រការ ១
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ



Scanned with CamScanner